# តួនាទី និង ភារកិច្ចរបស់មន្ត្រីបង្គោលសម្រាប់ កម្មវិធីពិពិធកម្ម និង ពង្រីកការនាំចេញរបស់កម្ពុជា ជំហានទី ១ - គម្រោងសមាសភាគសូត្រប្រណិត

( CEDEP I – High Value Silk Component )


**រៀបចំដោយ ៖ កញ្ញា ប៉ូ រតនា**

**មន្ត្រី M&E និង ជាមន្ត្រី Core Team**

# មាតិកា

1. សមាសភាគសូត្រប្រណិត( High Value Silk Component )
2. តួនាទី និង ភារកិច្ចរបស់មន្ត្រីបង្គោល
3. អត្ថប្រយោជន៍និង បទពិសោធន៍ ដែលទទួលបានពីការអនុវត្តន៍គម្រោង
4. សំនួមពរ

# 1. គម្រោងសូត្រប្រណិត ( High Value Silk Component )

- **គោលបំណង** : ជម្រុញ ធ្វើពិពិធកម្មនាំចេញ និង បង្កើនការប្រកួតប្រជែង ក្នុងវិស័យសូត្រប្រណិត ដើម្បីកាត់បន្ថយភាពក្រីក្រ តាមយៈការបង្កើតការងារ និង កំណើនប្រាក់ចំណូល ជាពិសេសសម្រាប់ស្ត្រី ក្នុងវិស័យឧស្សាហកម្មសូត្រ ។
- **សកម្មភាព** : បណ្តុះបណ្តាលផ្នែកជាងកាត់ដេរ ជ្រើសរើសសរសៃសូត្រ បង្ហាត់បង្រៀនផ្នែកទីផ្សារ ការរចនាម៉ូត និង កែលម្អគុណភាព ការចូលរួមក្នុងពិព័រណ៍ពាណិជ្ជកម្ម ធ្វើកម្មសិក្សានៅក្រៅប្រទេស ការអភិវឌ្ឍផែនការនាំចេញរបស់ក្រុមហ៊ុន ។
- **លទ្ធផលរំពឹងទុក** : កំណើនផលិតផលសិប្បកម្មសូត្រប្រណិតនៅទីផ្សារ គុណភាព និង រចនាម៉ូតផលិតផលសិប្បកម្មសូត្រ
- **រយៈពេលអនុវត្ត** : ខែតុលា ឆ្នាំ ២០១២ ដល់ ខែតុលា ឆ្នាំ ២០១៥
- **ថវិកា** : ១,០០៥,៣៥៧ ដុល្លារ
- **អ្នកអនុវត្ត** : មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ ( ITC )
- **ភ្នាក់ងារសម្របសម្រួលគម្រោង** : នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ / ក្រសួងពាណិជ្ជកម្ម

# 2. តួនាទី និង ភារកិច្ចរបស់មន្ត្រីបង្គោលក្នុងគម្រោងសូត្រប្រណិត

## 2.1 ផ្នែកសម្របសម្រួលទូទៅ

- ប្រមូលធាតុចូល ពីនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីត្រៀមរៀបចំកិច្ចប្រជុំទៀងទាត់របស់ CEDEP
- ផ្សព្វផ្សាយព័ត៌មានរបស់គម្រោង ដែលអនុវត្តដោយ DICO ទៅកាន់មន្ត្រីក្រសួងពាក់ព័ន្ធ
- ចែករំលែកព័ត៌មានដល់មន្ត្រីរបស់ក្រសួងពាក់ព័ន្ធ ស្តីពីសំណើគម្រោងថវិកា និង ឱកាសបណ្តុះបណ្តាលផ្សេងៗ សម្រាប់មន្ត្រីពាក់ព័ន្ធ
- សម្របសម្រួលរៀបចំកិច្ចប្រជុំ និង ប្រឹក្សាយោបល់ជាមួយក្រសួងពាក់ព័ន្ធ ជាពិសេសជាមួយមន្ត្រីរបស់ EIF ( UNOPS និង លេខាធិការដ្ឋានរបស់ EIF )

## 2. 2 ផ្នែកត្រួតពិនិត្យនិងវាយតម្លៃ

- សម្រួលការងារត្រួតពិនិត្យ និង វាយតម្លៃ ដើម្បីឲ្យមន្ត្រីពាក់ព័ន្ធយល់ដឹងកាន់តែច្បាស់ ពីគោលបំណង ទិសដៅ និងសូចនាករអនុវត្តគម្រោងក្រោមកម្មវិធី EIF
- ប្រមូលព័ត៌មានទាក់ទងនឹង M&E មកពីបណ្តាក្រសួងពាក់ព័ន្ធ ធ្វើជាធាតុចូលសម្រាប់របាយការណ៍ M&E របស់ DICO

## 3. អត្ថប្រយោជន៍ និង បទពិសោធន៍ដែលទទួលបានពីការអនុវត្តគម្រោង

- ពង្រឹងភាពជាដៃគូជិតស្និត និង បង្កើតបណ្តាញការងារ រវាងអង្គភាពរដ្ឋាភិបាល និង អង្គការសហប្រជាជាតិនៅកម្ពុជា ព្រមទាំងបណ្តាប្រទេស EIF
- មានឱកាសចូលរួមកម្មវិធីកសាងសមត្ថភាព ក្រោមជំនួយឧបត្ថម្ភរបស់ CEDEP តាមរយៈ សិក្ខាសាលា (ការអនុវត្តពាណិជ្ជកម្ម ការនាំចេញ ពាណិជ្ជកម្មក្រៅប្រទេស និង ធុរៈកិច្ច ) ទាំងនៅក្នុងស្រុក និង ក្រៅប្រទេស
- ចូលរួមធ្វើទស្សនៈកិច្ចសិក្សា ពិព័រណ៍ពាណិជ្ជកម្មនានា រៀបចំឡើងដោយអង្គភាពអនុវត្តគម្រោង CEDEP



ពិធីថតរូបរួមគ្នាក្នុងកម្មវិធីបណ្តុះបណ្តាល M&E និង Communication នៅបាងកក ប្រទេសថៃ



កម្មវិធីផ្លាស់ប្តូរទស្សនៈកិច្ចសិក្សា រវាងកម្ពុជា និង សឡាវ នៅទីក្រុង ហ្លួងព្រះបាង ប្រទេសឡាវ

# 3. សំនូមពរ

- សមាជិក Core Team គួរបង្កើនកិច្ចសហការគ្នា និងជួយចែករំលែកព័ត៌មានអោយគ្នាទៅវិញទៅមក ស្តីពីការអនុវត្តគម្រោង
- MIEs គួរបង្កើតកម្មវិធីកសាងសមត្ថភាពបន្ថែមទៀត សម្រាប់សមាជិក Core Team លើផ្នែកការគ្រប់គ្រងគម្រោង ត្រួតពិនិត្យ និង វាយតម្លៃ ក៏ដូចជាផ្នែកទំនាក់ទំនង
- ក្រសួងពាក់ព័ន្ធគួរកាត់បន្ថយភាពស្មុគស្មាញលើបែបបទរដ្ឋបាល ដើម្បីសម្រួលដល់សមាជិក Core Team ក្នុងការចូលរួមកិច្ចប្រជុំជាមួយអ្នកអនុវត្តគម្រោង និង DICO

# អរគុណ